cm.11-01-2002

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ១៣៥. សជណ . សរ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២

## សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
## នាថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០២

កាលពីថ្ងៃសុក្រ ទី ១១ ខែ មករា ឆ្នាំ ២០០២ វេលាម៉ោង ៨ និង ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដើម្បីពិភាក្សាលើ ÷

១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ

២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង

៣-បញ្ហាផ្សេងៗ

### ១-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ

គណៈរដ្ឋមន្ត្រីបានសំរេច :

១.១-អបអរសាទរ និងកោតសរសើរចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលបានខិតខំរៀបចំតាក់តែង នូវសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ តាំងពីឆ្នាំ ១៩៩៥ ព្រមទាំងបានសំរបសំរួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រហូតដល់បានសំរេចមកដាក់ឆ្លងប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅពេលនេះ មានរយៈពេលយ៉ាងយូរដល់ទៅ ៧ ឆ្នាំមកហើយ ។ សេចក្តីព្រាងច្បាប់នេះ បានចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ និងកំណែទំរង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ ដែលមានល្បឿនយឺតជាងគេ បើប្រៀបធៀបទៅនឹងកំណែទំរង់វិស័យដទៃទៀត ហើយពិសេសដើម្បីជំរុញវិស័យវិនិយោគនៅកម្ពុជាអោយកាន់តែរីកចំរើនថែមទៀត ។

១.២-កែសំរួលមាត្រា២ ក្នុងជំពូកទី១ ទៅជា : " រោងចក្រដែលមានចែងនៅក្នុងច្បាប់នេះ សំដៅទៅលើអាគារ ទីកន្លែង ឬយានយន្តសំរាប់ផលិត បំប្លែងវត្ថុធាតុដើម ឬផលិតផលពាក់កណ្តាលសំរេចអោយទៅជាផលិតផលថ្មី ២៨

ឬសំរាប់ធ្វើសកម្មភាពផ្សេងទៀត ដែលជាអាទិ៍មាន ផ្គុំដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ច្រកបំពេញ ថែទាំ រក្សាទុក កែលំអ ដើម្បីបំរើសេចក្តីត្រូវការទីផ្សារ ដោយប្រើប្រាស់កម្មករ និយោជិត ចាប់ពី ៥០ នាក់ឡើងទៅ " ។

១.៣-កែសំរួលមាត្រា៣ ក្នុងជំពូកទី១ ទៅជា " សិប្បកម្ម ដែលមានចែងនៅក្នុងច្បាប់នេះសំដៅទៅលើ អាគារ ទីកន្លែង ឬយានយន្តសំរាប់ផលិត បំប្លែងវត្ថុធាតុដើម ឬនិងសំរាប់ធ្វើសកម្មភាពផ្សេងទៀតដែលជាអាទិ៍ មានផ្គុំដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ច្រកបំពេញ ថែទាំ រក្សាទុក កែលំអ ដើម្បីបំរើសេចក្តីត្រូវការទីផ្សារ ដោយប្រើប្រាស់កម្មករ និយោជិត ចាប់ពី ១១ នាក់ ទៅដល់ ៤៩ នាក់ ។"

១.៤-កែសំរួលចំណុចទី ៧ នៃមាត្រា៤ ក្នុងជំពូកទី១ ទៅជា " ផ្នែកកែច្នៃលោហៈ ម៉ាស៊ីន និងគ្រឿងបរិក្ខារ " ។

១.៥-កែសំរួលត្រេទី៣ នៃមាត្រា៥ ក្នុងជំពូកទី១ ទៅជា "ធុនតូចមានតំលៃចាប់ពី ៣០០.០០០.០០០ រៀល (បីរយលានរៀល ) ដល់ ១.០០០.០០០.០០០ រៀល ( មួយពាន់លានរៀល ) " ។

១.៦-បង្កើតត្រេទី ៤ ថ្មី នៅក្នុងមាត្រា៦ ជំពូកទី២ ដែលមានខ្លឹមសារដូចតទៅ : " - វត្ថុធាតុដើមបំរើអោយការផលិត ។"

១.៧-កែសំរួលមាត្រា៩ ទៅជា " មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម អោយបានមុនរយៈពេល១៥ ( ដប់ប្រាំ ) ថ្ងៃ យ៉ាងតិច ។"

១.៨-លុបចោលពាក្យ "អំណាច " ហើយជំនួសវិញដោយពាក្យ "សិទ្ធិ " នៅក្នុងបន្ទាត់ទី១ នៃមាត្រា៣៧ ជំពូកទី៥ ។

១.៩-នៅមាត្រា ៣៩ ក្នុងជំពូកទី៥ បង្កើតត្រេទី១ថ្មី ដែលមានខ្លឹមសារដូចតទៅ: "- មានកំហុសឆ្គងធ្ងន់ធ្ងរ ផ្នែកបច្ចេកទេសដូចមានចែងក្នុងមាត្រា ២៤ " ។

១.១០-ក្រៅពីការកែសំរួល និងបំពេញបន្ថែមខាងលើ គណៈរដ្ឋមន្ត្រីបានឯកភាពទាំងស្រុងតាមខ្លឹមសារនៃ សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ ដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអង្គប្រជុំអន្តរក្រសួង បានស្នើឡើងមកនេះ ។

១.១១-ប្រគល់ភារកិច្ចជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលសហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ធ្វើការ កែសំរួលសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រនេះឡើងវិញ អោយបានសមស្របតាមការសំរេច របស់សម័យ ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ហើយត្រូវត្រៀមទៅការពារសេចក្តីព្រាងច្បាប់នេះនៅស្ថាប័ននីតិបញ្ញត្តិ ។

**២-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនាងក្បាក ខេត្តកោះកុង**

គណៈរដ្ឋមន្ត្រីបានសំរេច : *អ*

២.១-កោតសរសើរចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលបានខិតខំរៀបចំតាក់តែងសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង ដែលជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្ម សំដៅជំរុញវិនិយោគិនបរទេស អោយមកបណ្តាក់ទុនរកស៊ីនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅតំបន់ជាប់ព្រំដែនកម្ពុជា-ថៃអោយកាន់តែច្រើនឡើង ។

ចំពោះការរក្សាស្ថានភាពដដែលនៅតាមខ្សែបណ្តោយបន្ទាត់ព្រំដែននោះ គណៈរដ្ឋមន្ត្រីពុំមានការបារម្ភទេពីព្រោះម្យ៉ាងតំបន់ឧស្សាហកម្មនាងកុកនេះ ស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងម្យ៉ាងវិញទៀតទំរាំនឹងតំបន់ឧស្សាហកម្មនាងកុកកើតចេញជារូបរាង ការបោះបង្គោលព្រំដែន អាចនឹងបោះរួចជាស្ថាពរដែរ តាមការសន្យារបស់ឯកឧត្តម **ថាក់ស៊ីន ស៊ីណាវ៉ាត្រា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ ថាបញ្ហាព្រំដែនកម្ពុជា-ថៃ ត្រូវតែដោះស្រាយអោយចប់ក្នុងអាណត្តិនេះ ។

២.២-មាត្រា២ លុបចោលពាក្យ ( ប្រមាណ) នៅឃ្លាទី១ ។

២.៣-មាត្រា៣ កែសំរួលពាក្យ " មាត្រា២ "ទៅជា "មាត្រា៣ " នៅក្នុង នៃឃ្លាបន្ទាត់ទី១ ។

២.៤-ក្រៅពីការ កែសំរួលខាងលើ គណៈរដ្ឋមន្ត្រីបានសំរេចឯកភាពទាំងស្រុងតាមខ្លឹមសារ នៃសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តកោះកុង និងអង្គប្រជុំអន្តរក្រសួងបានស្នើឡើងមកនេះ ។

២.៥-ប្រគល់ភារកិច្ចជូនអភិបាលខេត្តកោះកុង ខិតខំដោះស្រាយគោលនយោបាយចំពោះម្ចាស់ដីស្របច្បាប់ដែលរដ្ឋបានដកហូតយកមកបង្កើតតំបន់ឧស្សាហកម្មនាងកុកនេះ ។

## ៣-បញ្ហាផ្សេងៗ :

គណៈរដ្ឋមន្ត្រីបានសំរេច :

៣.១-ប្រគល់ភារកិច្ចជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ធ្វើវិសោធនកម្មមាត្រាមួយចំនួនក្នុងច្បាប់ស្តីពីការងារ អោយសមស្របទៅតាមខ្លឹមសារនៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្របន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

៣.២-ប្រគល់ភារកិច្ចជូនសាលាក្រុងភ្នំពេញ ធ្វើការជួសជុលផ្លូវចំនួន ៤ ខ្សែ អោយបានទាន់ទាន់មុនពេលប្រជុំអាស៊ានខាងមុខនេះ គឺ :

- មហាវិថីសហព័ន្ធរុស្ស៊ី ពីផ្លូវ បំបែកចោមចៅ ដល់មហាវិថីព្រះនរោត្តម ។
- មហាវិថីព្រះនរោត្តម ពីវត្តភ្នំ ដល់រង្វង់មូលក្បាលថ្នល់ ។ ៧៨

- កំណាត់ផ្លូវសុធារស ពីវត្តឧណ្ណាលោម កាត់តាមមុខព្រះបរមរាជវាំង មុខរដ្ឋសភា មកទល់មហាវិថីព្រះសុរាម្រិត និងកំណាត់ផ្លូវព្រះសុរាម្រិត ពីវិថីសុធារសដល់វិមានឯករាជ្យ ព្រោះផ្លូវនេះខូចខាតច្រើន ហើយភ្ញៀវ ចេញ-ចូល ព្រះបរមរាជវាំង និងរដ្ឋសភា តាមផ្លូវនេះ ។

- មហាវិថីគីមអ៊ីលស៊ុង ពីមហាវិថីសហព័ន្ធរុស្ស៊ី ដល់រង្វង់មូលអង់តែនទូរទស្សន៍ ទួលគោក ។

សរុបទាំងអស់ចំនួន ៤ ខ្សែ ដែលត្រូវជួសជុលធំ ប៉ុន្តែដោយការងារនេះមានលក្ខណៈបន្ទាន់ សាលាក្រុងភ្នំពេញត្រូវប្រមែប្រមូលគ្រឿងចក្រអោយដំណើរការតែម្តង ដោយមិនបាច់ដាក់អោយដេញថ្លៃទេ គឺគ្រាន់តែធ្វើការពិគ្រោះថ្លៃដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ថវិកាជូនសាលាក្រុងភ្នំពេញ ដើម្បីដំណើរការជួសជុលផ្លូវខាងលើនេះអោយបានឆាប់រហ័ស ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើសុំឥណទានពីភាគីចិនសំរាប់ជួសជុលមហាវិថីម៉ៅសេទុងនាពេលខាងមុខផងដែរ ។

៣.៣-ប្រគល់ភារកិច្ចជូនក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសហការជាមួយសាលាខេត្ត-ក្រុងធ្វើការណែនាំ និងត្រួតពិនិត្យរាល់ផ្លាកយីហោរោងចក្រ សហគ្រាស ហាងលក់ទំនិញ ភោជនីយដ្ឋាន សណ្ឋាគារ ។ល។ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវតែសរសេរអក្សរខ្មែរ អោយបានធំជាងអក្សរបរទេស ហើយដាក់នៅជួរខាងលើគេបំផុត ។ កិច្ចការនេះត្រូវធ្វើជាបន្ទាន់ ដោយត្រូវចាប់ផ្តើមពីរាជធានីភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុមុនគេ ហើយត្រូវអនុវត្តអោយបានរៀបរយទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល៦ខែយ៉ាងយូរបំផុត ។ ក្នុងពេលអនុវត្ត បើសិនជាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈពិនិត្យឃើញថា មានការខ្វះខាតលិខិត បទដ្ឋានគតិយុត្តណាមួយនោះ ត្រូវរៀបចំបំពេញបន្ថែមអោយបានឆាប់រហ័សបំផុត ។ ទន្ទឹមនឹងនោះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសហការជាមួយក្រសួងពត៌មាន ក៏ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យ និងធ្វើការ ណែនាំដល់ក្រុមហ៊ុនទាំងឡាយ ដែលធ្វើការផ្សព្វផ្សាយគ្រប់មុខ ទំនិញ តាមកញ្ចក់ទូរទស្សន៍ គឺត្រូវតែរៀបចំថតនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយមានតួសំដែងជាសិល្បករ សិល្បការិនី ខ្មែរចូលរួម ហើយហាមឃាត់ការយករូបភាព និងតួសំដែងបរទេសមកបញ្ចាំងផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ដូចរយៈពេលកន្លងមក ។

៣.៤-ប្រគល់ភារកិច្ចជូនក្រសួងពត៌មានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ធ្វើការក្រើនរំលឹកដល់គ្រប់ស្ថានីយ៍ទូរទស្សន៍ ដោយមិនត្រូវអនុញ្ញាតអោយសិល្បការិនីស្លៀកពាក់មិនសមរម្យក្នុងកម្មវិធីផ្សាយបន្តផ្ទាល់ ដូចជាខោខ្លីពេក វាលកធំពេក ឬ ស្លៀកពាក់រហូសហែក ដែលបណ្តាលអោយប៉ះពាល់ដល់ទំនៀមទំលាប់នឹងវប្បធម៌ប្រពៃណីជាតិ ។ បើស្ថានីយ៍ទូរទស្សន៍ណាមិនព្រមអនុវត្តតាមការណែនាំខាងលើនេះ ក្រសួងពត៌មានត្រូវផ្អាកការផ្សាយបន្តផ្ទាល់មួយរយៈ ហើយបើនៅតែផ្គើន ត្រូវបិទជាស្ថាពរនូវការផ្សាយបន្តផ្ទាល់នេះ ។ ៤៩

៣.៥-ប្រគល់ភារកិច្ចជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្មសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធ្វើការពង្រាយរោងចក្រ សហគ្រាសនានាអោយបានកាន់តែទូលំទូលាយថែមទៀត ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលរស់នៅតាមជនបទ អោយមានការងារធ្វើ និងជៀសវាងនូវការប្រមូលផ្តុំធ្លាកកកុញនៅតែតាមទីក្រុងធំៗដូចជារាជធានីភ្នំពេញជាដើម ។

៣.៦-មិនអនុញ្ញាតអោយសាងសង់រោងចក្រស៊ីម៉ង់នៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលទេ ពីព្រោះវាអាចប៉ះពាល់ដល់បរិស្ថានសង្គម ធ្វើអោយខូចសុខភាពដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ និងបង្កអោយទ្រុឌទ្រោមខូចផ្លូវជាតិ ដោយការដឹកថ្មជាវត្ថុធាតុដើមពីភ្នំនានាមកចូលរោងចក្រ ។

៣.៧-ប្រគល់ភារកិច្ចជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ ទីតាំងសំរាប់បង្កើតតំបន់ឧស្សាហកម្មនៅប៉ោយប៉ែត ក្នុងខេត្តបន្ទាយមានជ័យ និងក្រុងប៉ៃលិនអោយបានឆាប់រហ័ស ដើម្បីទាក់ទាញការវិនិយោគពីសំណាក់បរទេស ជាពិសេសពីព្រះរាជាណាចក្រថៃ ដែលបានបាត់បង់ភាពអនុគ្រោះខាងពាណិជ្ជកម្មពីសហគមអឺរ៉ុប និងអាមេរិក ។

៣.៨-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខិតខំរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីជលផលថ្មីមួយអោយបានឆាប់រហ័ស ដើម្បីរួមចំណែកការពារមច្ឆាជាតិ បំរើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងទប់ស្កាត់នូវអំពើល្មើសច្បាប់ទាំងខាងអ្នកនេសាទ និងមន្ត្រីត្រួតពិនិត្យជលផលពីព្រោះក្រឹត្យ-ច្បាប់ចាស់នោះ បានហួសសម័យទៅហើយ ។ ចំពោះមុខក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវយកចិត្តទុកដាក់ណែនាំមន្ត្រីជលផល ត្រូវខិតខំអនុវត្តអោយបានត្រឹមត្រូវតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ត្រូវជៀសវាងនូវការគាបសង្កត់ដល់អ្នកនេសាទ ជាអាទិ៍ ការហាមឃាត់ការអូសអួនដោយម៉ាស៊ីនជាដើម ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ បើមន្ត្រីជលផលរូបណានៅតែហាមឃាត់អ្នកនេសាទមិនអោយអូសអួន ដោយម៉ាស៊ីនតទៅទៀត គឺត្រូវមានវិធានការជាបន្ទាន់ទៅតាមទោសកំហុសរបស់មន្ត្រីជលផលនោះ ។

៣.៩-ប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បើកផ្តល់ថវិកាជូនគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ដើម្បីអោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០០២ ខាងមុខនេះទទួលបានជោគជ័យ ។ ទន្ទឹមនឹងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកាត់យកថវិកាមួយចំនួន ដែលបានមកពីការដេញថ្លៃលក់កូតានាំចេញសំលៀកបំពាក់ ដើម្បីបើកបៀវត្សជូនមន្ត្រីរាជការអោយបានទាន់ពេលវេលា ។

៣.១០-សម្តេចប្រមុខរាជរដ្ឋាភិបាលបានប្រកាសជាចំហរថា ក្នុងពេលធ្វើការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នាពេលខាងមុខ សម្តេចនាយករដ្ឋមន្ត្រីនឹងមិនចូលរួមបោះឆ្នោត និងធ្វើការឃោសនាសំរាប់បោះឆ្នោត ./៨

នេះឡើយ ដើម្បីបង្ហាញពីភាពអព្យាក្រឹត្យរបស់អ្នកកាន់អំណាច ។ សម្តេចនាយករដ្ឋមន្ត្រីនឹងចូលរួមតែក្នុងការសម្ពោធសមិទ្ធិផលថ្មីៗ ដូចជាផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ សាលារៀន មន្ទីរពេទ្យតែប៉ុណ្ណោះ ។

៣.១២-ប្រគល់ភារកិច្ចជូនទីចាត់ការគយ និងរដ្ឋាករ រតនាគារជាតិ និងធនាគារជាតិនៃកម្ពុជា ធ្វើរបាយការណ៍ ស្តីពីចំណូលពន្ធគយ ស្ថានភាពថវិកា និងអត្រាប្តូរប្រាក់ប្រចាំថ្ងៃ ជូនសម្តេចនាយករដ្ឋមន្ត្រីអោយបានទៀងទាត់រៀង រាល់ថ្ងៃ ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងសាលាខេត្ត-ក្រុង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន ។ ៚

**ចំលងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**